# ដំណាំល្ង

## ១. ប្រវត្តិរបស់ដំណាំល្ង

ល្ង គឺជាដំណាំមួយក្នុងចំណោមដំណាំដែលមានវ័យចាស់ៗជាងគេនៅលើពិភពលោក ។ វាស្ថិតក្នុងគ្រួសារ *Pedaliceac* និងត្រូវបានអ្នកវិទ្យាសាស្រ្តហៅឈ្មោះថា *Sesamumindicuml* ។ ដំណាំនេះត្រូវបានគេឃើញដំបូងនៅឧបទ្វីបអាព្រិច និងក្រោយមក ត្រូវបានដាំនៅប្រទេសឥណ្ឌា ដោយឡែកនៅសហរដ្ឋអាមេរិកត្រូវបានណែនាំអោយដាំ នៅឆ្នាំ 1930 ប៉ុន្តែរហូតដល់ឆ្នាំ1950 ក៏ត្រូវបានដាំយ៉ាងពេញលេញនៅរដ្ឋតិចសាសន៍លើ ផ្ទៃដីប្រមាណជា 40គម២ទៅ 80គម២រៀងរាល់ឆ្នាំ។ ចាប់ពីឆ្នាំ2007រហូតដល់បច្ចុប្បន្នបណ្តា ប្រទេសដែលនិយមដាំមានដូចជាឥណ្ឌា ចិន មីយ៉ាន់ម៉ា សូដង់ មិចស៊ិច វេនេសួអេឡា ។ តាមទិន្នន័យដែលផ្តល់ជូននៅឆ្នាំ1987 គឺមាន 2.53 លានតោន។ ជាទិន្នផលសរុបសំរាប់ ពិភពលោកលើផ្ទៃដី16,3លានអា។ ក្នុងនោះនៅអាស៊ីប្រមាណជា 70 % និងនៅអាព្រិច 26 % ។ ដូចនេះយើងឃើញថា ដំណាំល្ងនេះជាដំណាំមួយប្រភេទដែលមានសារសំខាន់ សំរាប់បណ្តាប្រទេសមួយចំនួននៅលើពិភពលោក ជាពិសេសក្នុងពេលបច្ចុប្បន្ន។ រីឯ ប្រទេសកម្ពុជាយើងដែលជាប្រទេសផ្តោតទៅលើវិស័យ កសិកម្មជាចំបងក្នុងការ អភិវឌ្ឍន៍ប្រទេសជាតិត្រូវបានបង្ហាញឲ្យមានដំណាំល្ងនេះផងដែរ។

នៅឆ្នាំ 1943 ត្រូវបានដាំគ្របដណ្តប់លើផ្ទៃដីប្រមាណជា 750 ហិចតា ភាគច្រើននៅ តាមត្រពាំង ទន្លេ ខេត្តកណ្តាល បន្ទាប់មកដល់ខេត្តកំពង់ចាម ក្រចេះ និងតំបន់ខ្ពង់រាប ។

ពូជពីរប្រភេទត្រូវបានរកឃើញគឺ ប្រភេទល្ង ស និងប្រភេទល្ង ខ្មៅ ហើយដោយពូជ ទាំងពីរនេះមានអាយុកាលលូតលាស់ផ្សេងៗគ្នា គឺពូជ ស មានអាយុកាលខ្លីជាងពូជខ្មៅ។ ពូជស រយៈកាលចាប់ពីដាំដល់ប្រមូលផលគឺ 3 ខែ រីឯពូជខ្មៅ អាចមានរយៈពេល រហូតដល់4ខែ ទើបអាចប្រមូលផល។

## ២. ផលប្រយោជន៍

ថ្វីបើដំណាំល្ងជាដំណាំដែលមានគ្រាប់តូចៗ តែជាដំណាំដែលពោរពេញទៅដោយ សារធាតុចិញ្ចឹមសំរាប់ទ្រទ្រង់រាងកាយរបស់មនុស្ស និងសត្វ ។ ប្រូតេអ៊ីនត្រូវបានរក ឃើញថាមាន 25 % ដែលមានសារសំខាន់សំរាប់ការលូតលាស់របស់មនុស្ស និងសត្វ មិនតែប៉ុណ្ណោះ ដែក កាល់ស្យូម កាបូនអ៊ីដ្រាត វីតាមីនB1 ដែលជាសារធាតុចាំបាច់ដល់ មនុស្សសត្វក៏ត្រូវចង្អុល បង្ហាញថាមានចំនួនដ៏ច្រើនផងដែរ។ ប្រេងមានអត្រាខ្ពស់ជាង គេ(50%)ហើយនឹងមានអត្រា កាន់តែខ្ពស់ប្រសិនបើប្រូតេអ៊ីនថយចុះ។ រីឯល្ង ស ជាប្រភេទ ល្ងដែលមានសារធាតុប្រេងខ្ពស់ជាងប្រភេទល្ងដទៃទៀត ប៉ុន្តែបើធ្វើការសំងួតប្រេងវិញ នឹងធ្វើឲ្យប្រូតេអ៊ីនកើនឡើងវិញ។

ដោយសារបច្ចេកវិទ្យាកើន ដូចនេះដំណាំល្ងត្រូវបានប្រទេសជាច្រើននៅលើ ពិភពលោកមានការចាប់អារម្មណ៍សំរាប់ការកែច្នៃជាឧបករណ៍ប្រើប្រាស់។ ប្រេងរបស់វា អាចចំរាញ់ធ្វើជាប្រេងឆាសំរាប់ចំអិនអាហារផ្សេងៗ ហើយវាក៏ដើរតួនាទីយ៉ាងសំខាន់ ជាវត្ថុធាតុដើមសំរាប់ផលិតជាសាប៊ូដុសខ្លួន សាប៊ូកក់សក់ ថ្នាំលាប ទឹកអប់។ ផ្នែកវិជ្ជសាស្ត្រប្រទេសជាច្រើនយកល្ង មកធ្វើជាឱសថក្នុងការព្យាបាលជំងឺផ្សេងៗតាម ការនិយមរបស់ខ្លួន ។ យ៉ាងណាមិញដើម្បីកំចាត់សត្វល្អិត គេក៏បានកែច្នៃល្ងដែលមាន ឥទ្ធិពលយ៉ាងប្រសិទ្ធិភាពទៅដល់ការកំចាត់កត្តាចង្រៃផងដែរ។ ដោយឡែកប្រទេសកូរ៉េដែលជាប្រទេសរីកចំរើនខាងឧស្សាហកម្មម្ហូបអាហារ ក៏បានប្រើ ប្រាស់នូវស្លឹករបស់ល្ងសំរាប់ធ្វើជាគ្រឿងផ្សំម្ហូបផ្សេងៗដ៏មានឱជារស ។ ម្យ៉ាងវិញ ទៀតបរទេសខ្លះយកល្ងដើម្បីធ្វើនំប៉័ង ប៊ី ស្ករគ្រាប់ និងម្ហូបអាហារទៅតាមទំនៀមទំលាប់ រៀងៗខ្លួន។ ដោយឡែកប្រទេសកាន់សាសនាធំៗមួយចំនួនក៏និយមប្រើប្រាស់ល្ងជា ដង្វាយទៅតាមការនិយមនៃសាសនានីមួយៗ ។ សាសនាហិណ្ឌូ ព្រះពុទ្ធ សុទ្ធតែងដើរ តួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តន៏ តាមវិធីសាសនា ដោយយកគ្រាប់របស់វារៀបតាមរបៀប ឬ តាមកិច្ចរៀងៗខ្លួន។ រីឯប្រទេសកម្ពុជាយើងដែលតែងតែអនុវត្តន៏របៀបសការៈ ផ្សេងៗតាមសាសនាយ៉ាងខ្ជាប់ខ្ជួន ហើយក៏ជាប្រទេសកាន់សាសនាពីរស្របគ្នា គឺសាសនា ហិណ្ឌូ និង សាសនាព្រះពុទ្ធ ក៏បានយកគ្រាប់ល្ងធ្វើជាដង្វាយផងដែរ។ ម្យ៉ាងវិញទៀត តាំងពីបុរាណរហូតដល់បច្ចុប្បន្នដំណាំល្ង (ដើម) ក៏បានប្រើប្រាស់ជាដំណាំសំរាប់ជួយ កែប្រែដីឲ្យមានជីវជាតិល្អ។ ដូចនេះ ប្រជាកសិករបានប្រើប្រាស់វាជាប្រភពធនធាន យ៉ាងសំខាន់ក្នុងការធ្វើជាជីកំប៉ុស្ត៍យ៉ាងមានប្រសិទ្ធភាព។

# ៣. លក្ខណៈរូបសាស្រ្តដំណាំល្ង



### ក. ឫស

ឫសដើរតួនាទីយ៉ាងសំខាន់សំរាប់ទប់ដងដើម មិនអោយដួលរលំ ធ្វើអោយដើមមាំ ល្អ ស្រូបយកទឹកអំបិលខនិជជាអ្នកដឹកនាំនូវសារធាតុផ្សេងៗតាមរយៈបន្សាយ និងអ៊ូស្មូស ជា កន្លែងផ្ទុកនូវអាហារបំរុង ការបន្តពូជដោយភេទនិងជាប្រព័ន្ធដកដង្ហើមយ៉ាងសំខាន់ ផងដែរ។ ឫសកែវមានសារសំខាន់សំរាប់ទប់ដើមអោយត្រង់ល្អ មិនអោយដួករលំ ដោយ វាអាចចាក់ចូលក្នុងដីបានជំរៅ 1 m .

### ខ. ដើម

ដើមមានលក្ខណៈស្រួយប្រហោងក្នុង និងដុះត្រង់ល្អ ប្រភេទខ្លះមានមែក ប្រភេទខ្លះទៀតពុំមានទេ ។ វាអាចមានកំពស់ចាប់ពីរ 50 cm ទៅ 100 cm អាចរាងមូល ឬជ្រុង។ ដើម ដើរតួនាទីយ៉ាងសំខាន់សំរាប់ទ្រទ្រង់ស្លឹកនិងផ្កា ដឹកនាំសារធាតុផ្សេងៗ ជាអ្នកផ្ទុកអាហារបំរុងនិង ជាអ្នកផលិតអាហារយ៉ាងសំខាន់។



*ដើមល្ង*

### គ. ស្លឹក

ស្លឹកមានរាងត្រវែងស្រួចចុង ប្រភេទខ្លះមានរាងបេះដូង ហើយអាចឆែកនៅចុង ស្លឹក ។ វាអាចដុះឆ្លាស់គ្នានិងចាក់ទៅរកគ្នា ហើយអាចមានប្រវែងចាប់ពី 4 ទៅ 14 cm ។ មុខងាររបស់វាអាចផលិតអាហារបំលាស់ប្តូរឧស្ម័ន ។ បំភាយចំហាយទឹក និងការផ្ទុក អាហារ។




*ស្លឹកល្ង*

### ឃ. គ្រាប់

គ្រាប់មានរាងតូចល្អិត ហើយមានពណ៌ខ្មៅ ស ប្រផេះ ត្នោត តាមប្រភេទ។ វាអាច មានប្រវែងចាប់ពី ១.៥ ទៅ ៤ cm ។

### ង. ផ្កា

ផ្កាមានលក្ខណៈស៊ុំយលំអង ហើយមានពណ៌លឿង ខៀវ ស្វាយ ផ្កាឈូកទៅតាម ប្រភេទ។ វាអាចដុះនៅចន្លោះ ទងស្លឹក និងអាចមានប្រវែងចាប់ពី 15 ទៅ 38 mm ។





*ផ្កាល្ង*

### ច. ផ្លែ

ផ្លែមានរាងទ្រវែង ដោយក្នុងនោះអាចមានគ្រាប់ពី ៥០ ទៅ ១០០ គ្រាប់ ។ វាមាន ប្រវែងចាប់ពី 4 cm ទៅ 5 cm ហើយជារឿយៗតែងស្ថិតនៅក្នុងចន្លោះទងស្លឹកដែលមាន ចំនួនពី ៣ទៅ ៤ថត នៅពេលទុំសំបករបស់វាមានពណ៌ខ្មៅឬ ត្នោតចាស់និងចំហមាត់នៅ ផ្នែកខាងចុង ។



*ផ្លែខ្ចី*



*ផ្លែទុំ*

## ៤. លក្ខណៈជីវសាស្ត្រនៃដំណាំល្ង

### ១. សីតុណ្ហភាព

នៅក្នុងការសិក្សាស្រាវជ្រាវបានបង្ហាញឲ្យឃើញថាដំណាំល្ងត្រូវការសីតុណ្ហភាព ដែលសមស្របគឺពី២៥C°ទៅ២៦៦៧.C°។ឯនៅកំរិតសីតុណ្ហភាពក្រោម២០C°ការលូតលាស់របស់ល្ងត្រូវបានកាត់បន្ថយ។ហើយលើសពីនេះទៅទៀតប្រសិនបើសីតុណ្ហភាពធ្លាក់ចុះ រហូតដល់ក្នុងកំរិត១០C°។នោះនឹងធ្វើឲ្យការចេញពន្លកនិងការលូតលាស់របស់ដំណាំល្ងមិនអាច ដំណើរការបានឡើយ។

### ២. សំណើម

ដំណាំល្ងជាប្រភេទដំណាំដែលមានភាពស៊ូទ្រាំទៅនឹងភាពរាំងស្ងួតដោយពឹងផ្អែកទៅលើប្រព័ន្ធ ឬសរបស់វាចាក់ជ្រៅចូលទៅក្នុងដី។តែទោះបីយ៉ាងណាក៏ដោយវាក៏ត្រូវការសំណើមសម្រាប់ការដុះលូតលាស់ដែរ ដោយគេសន្និដ្ឋានឃើញថាកំរិតកម្ពស់ទឹកភ្លៀង ដែលមានលក្ខណៈសមស្របចំពោះវា គឺពី៥០៨មីលីម៉ែត្រទៅ៦៦០.៤មីលីម៉ែត្រក្នុងមួយវដ្ដ ជីវិតរបស់វា។ លើសពីនេះទៅទៀត គេកំណត់សំគាល់ឃើញថាកំរិតសំណើមច្រើន មុនពេលធ្វើការដំណុះ និងពេលដែលវាកំពុងចេញផ្កាគឺមានការប៉ះពាល់យ៉ាងខ្លាំងបំផុត ព្រោះវាមិនអាចធន់ទ្រាំនិងការដក់ទឹកជាប់បានយូរនោះទេ ។ ក្នុងករណីនេះវាអាចបង្កឲ្យ កើតជាជំងឺផ្សិតនិងជំងឺរលួយបានយ៉ាងងាយទៅលើគ្រាប់ ឬសនិងផ្កា។

### ៣. ខ្យល់

ល្បឿនខ្យល់ដែលសមស្របសម្រាប់ការដុះលូតលាស់របស់ដំណាំល្ង គឺពី៦០ទៅ ៧០ម៉ែត្រក្នុងមួយនាទី។ ប៉ុន្ដែវាអាចរងការប៉ះពាល់ប្រសិនបើមានកម្លាំងខ្យល់បក់ខ្លាំងជាង នេះជា ពិសេសនូវពេលដែលវាកំពុងស្ថិតនៅក្នុងដំណាក់កាលទុំ ព្រោះវាអាចបណ្ដាលឲ្យ គ្រាប់របស់ វាជ្រុះបាន។

### ៤. ពន្លឺ

ក្នុងដំណាក់កាលចេញផ្កាល្ងគឺវាងាយនិងទទួលរងនូវការប៉ះពាល់ជាមួយនិងពន្លឺព្រះ អាទិត្យខ្លាំងណាស់ ព្រោះគ្រាប់វាទន់ហើយស្ដើង។ ម្យ៉ាងវិញទៀតវាបណ្ដាលសារធាតុ ប្រេងក្នុងគ្រាប់ល្ងមានទំនោរទៅនិងការកើនឡើងនៃពន្លឺថ្ងៃ។ ដូចនេះសារធាតុប្រេងកើន ឡើងធ្វើឲ្យ សារធាតុប្រូតេអ៊ីនកើនឡើងដែរ។

**៥. ដី**

ដំណាំល្ងគឺជាដំណាំមួយប្រភេទដែលអាចដាំដុះនៅលើសណ្ឋានដីបានច្រើនប្រភេទ ប៉ុន្តែវាអាចដុះលូតលាស់ល្អនៅដីល្បាប់ដីដែលមានវាយនភាពល្អ មានជីជាតិ ហើយជាដី ដែលមានកំរិត pH ចន្លោះពី ៥ ទៅ ៧។ វាមានប្រព័ន្ធឬសសម្រាប់ដឹកនាំសារធាតុចិញ្ចឹម ពីក្នុងដីយ៉ាងល្អ។ ម្យ៉ាងវិញវាធ្វើឲ្យដីមានទំរង់ល្អផងដែរ ។ ដំណាំល្ងមានភាពធន់ទ្រាំ ទៅនិងដីដែលមានជាតិប្រៃទាបបំផុត ហើយវាមិនអាចធន់ទ្រាំនិងភាពជោគជាំនៃដីបានយូរ ឡើយ ។ ផ្ទុយទៅវិញវាមានភាពស៊ូទ្រាំនិងអាកាសធាតុស្ងួតបានយូរជាងដំណាំមួយ ចំនួននៅតំបន់ ត្រូពិច។

## ៥. ប្រភេទនៃដំណាំល្ង

ប្រភេទនៃដំណាំល្ងត្រូវបានគេចែកចេញជាពីរប្រភេទគឺៈ

-ល្ងស និង

-ល្ងខ្មៅ

ល្ងសគឺជាប្រភេទល្ងមានអាយុកាលដាំដុះខ្លីជាងល្ងខ្មៅ ឬក៏ស្រាលជាងល្ងខ្មៅ។ អាយុកាលរបស់វាពីការដាំរហូតដល់ប្រមូលផលវាមានអាយុកាល ៧០ថ្ងៃ ទៅ៩០ថ្ងៃ ទើប យើងអាចប្រមូលផលបាន ។

ល្ងខ្មៅគឺជាប្រភេទល្ងមានអាយុកាលដាំដុះវែងជាងល្ងស ឬក៏ធ្ងន់ជាងល្ងសអាយុ កាលរបស់វាពីការដាំរហូតដល់ប្រមូលផលវាមានអាយុកាល ៩០ថ្ងៃ ទៅ១៥០ថ្ងៃទើបយើងអាចប្រមូលផលបាន។

*ល្ងស* *ល្ងខ្មៅ*



## ៦. បច្ចេកទេសដាំ និងការថែទាំ

### ក. ការរៀបចំដី

មុននិងដាំដំបូងយើងត្រូវរៀបចំដីជ្រើសរើសប្រភេទដីទួលនិងមិនដក់ទឹកនៅរដូវ វស្សាជៀសវាង ការដាំទឹកនៅពេលដែលមានភ្លៀងធ្លាក់ជោគជាំច្រើននិងជ្រើសរើសដីទំ  នាបនៅរដូវប្រាំងជៀសវាងការ អត់ទឹកភ្លៀង។

ការភ្ជួររាស់: ការភ្ជួររាស់គេត្រូវការភ្ជួររាស់ពីពីរដងទៅបីដងមុននឹងធ្វើការដាំដុះ។

ភ្ជួរដីលើកទី ១  គេត្រូវភ្ជួរជំរៅពី ២ ទៅ ២,៥ តឹក។

ភ្ជួរដីលើកទី ២  មួយខែក្រោយពេលភ្ជួរលើកទី ១ ជំរៅ ១,២ ទៅ ២តឹក។ក្រោយពី ការភ្ជួររួចត្រូវ រាស់ពី ២ ទៅ ៣ដងទៀតធ្វើបែបនេះឲ្យដីម៉ត់ល្អនិងដីធូរមិនក្តាំងរឹង។

### ខ. ការជ្រើសរើសពូជ

ការជ្រើសរើសពូជគេត្រូវ  ជ្រើសរើសពូជណាដែលផ្តល់ទិន្នផលខ្ពស់  ហើយគ្មានជំងឺ  និងសត្វ ល្អិតបំផ្លាញ។គ្រាប់ពូជត្រូវតែសុទ្ធល្អ សាច់ណែនល្អមិនស្លៀតស្វិត។

### គ. ការដាំដុះ

មុននិងធ្វើការដាំដុះគេត្រូវយកគ្រាប់ល្ងដែលស្ងួតហាលថ្ងៃយ៉ាងតិចពី១ទៅ២ម៉ោងនៅក្រោម ពន្លឺថ្ងៃ   ដំណាំល្ងត្រូវបានគេដាំ២ដងក្នុងមួយឆ្នាំគឺរដូវវស្សាហើយនិងរដូវប្រាំង។

ការដាំដុះនៅរដូវវស្សាគេច្រើនដាំដុះនៅដើមរដូវវស្សានិងនៅពាក់កណ្តាលរដូវវស្សាគេចាប់ផ្តើម ដាំនៅរវាងខែកញ្ញានិង ខែតុលា។

ការដាំដុះនៅរដូវប្រាំងគេច្រើនដាំដុះនៅពាក់កណ្តាលរដូវប្រាំងនិងនៅចុងរដូវប្រាំងគេចាប់ផ្តើម ដាំនៅរវាងខែមិនានិង ខែមេសា។

ការដាំគេត្រូវដាំគំលាតពីជួរមួយទៅជួរមួយទៀតចំងាយពី៧០ស.មទៅ៧៥ស.ម។  និងចន្លោះ ពីគុម្ពមួយទៅគុម្ពមួយទៀតចំងាយ៥០ស.មនិងប្រើប្រាស់គ្រាប់ពី៧គីឡូទៅ  ៨គីឡូ/ហិចតា។  ជំរៅដី ដាក់គ្រាប់ពី២ស.មទៅ៣.៨ស.ម។

### ឃ. ការថែទាំ

ការដាក់ជីលាមកសត្វគឺដាក់ចំនួន២ទៅ៣តោន/ហិចតា(តាមសណ្ឋានដី)។ការដករំលោះកូន ដើមល្ង   គឺគេធ្វើឡើងនៅអាយុកូនល្ងបាន១៣ថ្ងៃក្រោយពីដាំដោយទុកតែកូនល្ង   ពី២ទៅ៣ដើមតែ ប៉ុណ្ណោះក្នុងមួយគុម្ព។ ហើយធ្វើការដកជំរះពួនគល់នៅពេលដែលល្ងបាន អាយុ២៣ថ្ងៃ ហើយការជំរះ ស្មៅពូនគល់ត្រូវធ្វើឡើងពី ១ ទៅ ២ដងក្នុងមួយវដ្តជីវិតរបស់ល្ង។

## ៧. សត្វល្អិត និង ជំងឺ

### ក. សត្វល្អិត

- សត្វ Aphids : ជាសត្វល្អិតម្យ៉ាងមានរាងសំប៉ែត ពណ៌ស មានជើងច្រើនដែល រស់នៅជញ្ជក់យករុក្ខរសពីរុក្ខជាតិ ។ ធ្វើឲ្យកូនល្ងលូតលាស់មិនពេញលេញ និង បំផ្លាញត្រួយផ្កាដែលមិនទាន់រីក។
- សត្វសុច មមង់និងដង្កូវមាស់ក៏ជាសត្វល្អិតបំផ្លាញដល់ដំណាំល្ងដែរ។
- ពីងពាងក្រហម កណ្តូប ដង្កូវ សុទ្ធតែរាតត្បាតនៅលើដើមល្ង តែមិនមានការ បំផ្លាញច្រើនឡើយទៅលើដំណាំល្ង។
- ស្រមោច (Ant)
  - ការបំផ្លាញៈ បឺតជញ្ជក់នូវទឹកដមដើមល្ង និងជា ពិសេសនោះគឺកូនល្ង នៅតូចៗ ។
  - ធ្វើឲ្យល្ងមានការលូតលាស់យឺត និងជាពិសេសនោះគឺការដុះលូតលាស់មិន ស្មើគ្នា ។



*ស្រមោចរមដើមល្ង*

- សត្វ Whiteflies
  - ការបំផ្លាញៈ
    - ចោះនិងបឺតជញ្ជក់នូវរុក្ខរសពីស្លឹក ធ្វើឲ្យដំណាំខ្សោយ និងកាត់បន្ថយ ការលូតលាស់ ។
    - ធ្វើឲ្យដំណាំប្រែពណ៌លឿង និងជ្រុះស្លឹក និងធ្វើឲ្យដំណាំងាប់។
    - ម៉្យាងវិញទៀតសត្វនេះបានបង្កើតផ្សិតនៅលើស្លឹក។



*សត្វ Whiteflies*

- ❖ វិធានការណ៍ការពារ
  - – កាដាំដំណាំឆ្លាស់
  - – ការដាំដំណាំរង្វិលជុំ
  - – ការជ្រើសរើសពូជដែលធន់នឹងសត្វល្អិត។

**ខ. ជំងឺ**

ជំងឺមានដូចជាជំងឺអុចស្លឹក(Leaf spot) ស្រពោនដើម(Stem blights) រលួយឬស (Root rot) ជំងឺរួញស្លឹក(Leaf curl) ជំងឺមួយចំនួនកើតឡើងនៅលើគ្រាប់ ។

- ❖ ជំងឺ Bacterial Leaf Spot
  - – បង្កដោយៈ បាក់តេរី *Pseudomonas syringae pv. sesami* ។
  - – ការបំផ្លាញៈ
    - • ធ្វើឲ្យស្លឹកមានស្នាមពណ៌ត្នោតចាស់ បន្ទាប់មករីករាលដាលដល់ដើម និងផ្លែ។
    - • ធ្វើឲ្យស្លឹកចាប់ផ្តើមធាយ និងងាប់ដើម។



*ជំងឺចុជស្លឹក Leaf spot*

- **ជំងឺ** Leaf-curl
    - បង្កដោយៈ មេរោគ *Nicotiana*
    - ការបំផ្លាញ
        - ស្លឹកចាប់ផ្តើមរួញ
        - ដំណាំមានការលូតលាស់យឺតយ៉ាវ។
- វិធានការណ៍ការពារ
    - ជ្រើសរើសពូជដែលធន់និងជំងឺ
    - ហាលដីឲ្យបានល្អ
    - ដាំដំណាំឆ្លាស់ ឬ ចំរុះ
    - ដាំដំណាំបង្វិល ។

## ៨. ការប្រមូលផល និង ការស្តុកទុក

### ក. ការប្រមូលផល

- ល្ងអាចប្រមូលផលបានបន្ទាប់ពីដាំបាន ៩០ថ្ងៃ ទៅ ១៥០ថ្ងៃ ។
- ត្រូវប្រមូលផលមុនពេលអាកាសធាតុត្រជាក់ខ្លាំងមកដល់ ដើម្បីទទួលបានគ្រាប់ល្ង ដែលមានគុណភាពខ្ពស់ ។
- ពេលល្ងទុំ ស្លឹកនិងដើមចាប់ផ្តើមប្រែពណ៌ពីបៃតងទៅលឿង ពីលឿងទៅក្រហម ហើយស្លឹកចាប់ផ្តើមជ្រុះពីដើម។
- គេតែងចងដើមល្ងជាកណ្តាប់ ឬ បាច់ ហើយដាក់បញ្ឈរត្រង់នៅមួយកន្លែង។
- កណ្តាប់ត្រូវចងឲ្យតឹងក្នុង២ឬ៣ថ្ងៃ។
- ក្នុងរយៈពេល២សប្តាហ៍គឺអាចបោកបែនបានហើយ។



*ការប្រមូលផល*

### ខ. ការស្តុកទុក

ល្ងត្រូវបានរក្សាទុកនៅកន្លែងងងឹតនិងមានសំណើមទាប ។ ប្រសិនបើរក្សាទុកនៅ លក្ខខ័ណ្ឌបែបនេះ ល្ងនឹងអាចរក្សាទុកបានរយៈពេលមួយឆ្នាំ។ សីតុណ្ហភាពត្រជាក់ខ្លាំងក៏ អាចបណ្តាលឲ្យខូចខាតដល់គ្រាប់ល្ងនិងធ្វើឲ្យល្ងគ្មានតំលៃនៅលើទីផ្សារឡើយ។

# ឯកសារយោង

ឯកសារ**ដំណាំល្ង**ដែលបានចងក្រងនិងបង្ហាញពីខាងលើទាំងប៉ុន្មាននោះ គឺបានមក ពីការស្រាវជ្រាវនិងដកស្រង់ចេញពី **Internet** និង ឯកសារមេរៀនដំណាំល្ងរបស់ **Lecturer : Seng Theara** ។

ឯកសារមួយភាគធំគឺបានដកស្រង់ចេញពីឯកសារមួយឈ្មោះថា **Alternative Field Crop Manual** ចេញដោយ University of Wisconsin-Extension, Cooperative Extension. University of Minnesota: Center for Alternative Plant & Animal Products and the Minnesota Extension Service. Last update December 2,1997

ទាក់ទងនិង**ប្រភេទនៃដំណាំល្ងនិងបច្ចេកទេសដាំដុះដំណាំល្ង** គឺទទួលបានពី កញ្ញា **សុទ្ធ រតនៈ** ដែលមានឪពុកម្តាយជាកសិករធ្លាប់ដាំដុះដំណាំល្ងនេះដែរ។

ទាក់ទងនិង**សត្វល្អិតនិងជំងឺ ការប្រមូលផលនិងការស្តុកទុក** គឺបានដកស្រង់ ចំណុចសំខាន់មួយចំនួនចេញពីឯកសារមេរៀនដំណាំល្ងរបស់ **Lecturer : Seng Theara** Master Candidate of Strategic Management. January 1,2008 ។